# ការស្ទង់មតិអំពីការប្រើប្រាស់ភាសា

មាតាបិតា/អាណាព្យាបាលជាទីគោរព៖

ការនិយាយភាសាបានច្រើនលើសពីមួយភាសាឡើងទៅ គឺជាទ្រព្យដ៏មានតម្លៃបំផុត។ យើងសូមជំរុញលើកទឹកចិត្តឱ្យគ្រួសារទាំងអស់បន្តរក្សាការប្រើប្រាស់ភាសាកំណើតរបស់ខ្លួន នៅពេលដែលកំពុងសិក្សាភាសាអង់គ្លេស។ សិស្សដែលនិយាយភាសាផ្សេង ឬអាចយល់ភាសាផ្សេងទៀតក្រៅពីភាសាអង់គ្លេសអាចមានសិទ្ធិទទួលបានជំនួយគាំទ្រដើម្បីកែលម្អភាសាអង់គ្លេសរបស់ពួកគេ និងជួយបំពេញតាមស្តង់ដារសិក្សារបស់ រដ្ឋ Maine។

សំណួរខាងក្រោមដែលតម្រូវឱ្យសិស្សទាំងអស់ចាប់ពីកម្រិតមត្តេយ្យសិក្សាដល់ថ្នាក់ទី 12 ត្រូវតែឆ្លើយឱ្យបានគ្រប់គ្នា នឹងជួយឱ្យសាលារៀនធ្វើការវាយតម្លៃដើម្បីសម្រេចថាតើកូនរបស់អ្នកអាចទទួលបានអត្ថប្រយោជន៍ពីការជួយគាំទ្រភាសាអង់គ្លេសដែរឬអត់។

ប្រសិនបើអ្នកចង់បានលិខិត និងការស្ទង់មតិខាងក្រោមនេះជាភាសាផ្សេងទៀតក្រៅពីភាសាអង់គ្លេស ឬប្រសិនបើអ្នកត្រូវការអ្នកបកប្រែ សាលារៀនរបស់អ្នកនឹងបំពេញតាមសំណើទាំងអស់នេះជូនអ្នក។ អ្នកមានសិទ្ធិស្របច្បាប់ក្នុងការទទួលបានការទំនាក់ទំនងណាមួយពីសាលារៀន ក្នុងទម្រង់ជាការសន្ទនាផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរជាភាសាដែលអ្នកអាចយល់បានល្អបំផុត។

ប្រសិនបើមានភាសាដទៃក្រៅពីភាសាអង់គ្លេសត្រូវបានបញ្ជាក់ខាងក្រោម កូនរបស់អ្នកនឹងត្រូវធ្វើតេស្តសមត្ថភាពភាសាអង់គ្លេស (ELP)។ កូនរបស់អ្នកអាចនឹងត្រូវបានកំណត់អត្តសញ្ញាណថាជាអ្នកសិក្សាភាសាអង់គ្លេស និងមានសិទ្ធិទទួលបានជំនួយភាសាអង់គ្លេស គឺអាស្រ័យទៅលើលទ្ធផលនៃការធ្វើតេស្តសមត្ថភាពភាសាអង់គ្លេសកូនរបស់អ្នកផ្ទាល់។ យើងសូមធានាថា ចម្លើយរបស់អ្នកនឹងត្រូវបានប្រើប្រាស់សម្រាប់តែគោលបំណងអប់រំប៉ុណ្ណោះ ហើយនឹងត្រូវបានរក្សាទុកនៅក្នុងឯកសារសាលារៀនរបស់កូនអ្នក ដែលមានតែបុគ្គលិកសាលារៀនតែប៉ុណ្ណោះដែលអាចចូលមើលបាន។ បុគ្គលិកសាលារៀនមិនត្រូវបានអនុញ្ញាតឱ្យសាកសួរអ្នកអំពីស្ថានភាពអន្តោប្រវេសន៍របស់គ្រួសារអ្នកទេ។

សូមអរគុណចំពោះការផ្តល់ព័ត៌មាននេះ និងសូមជូនពរឱ្យកូនរបស់អ្នកទទួលបានជោគជ័យក្នុងការសិក្សា។

| | |
|---|---|
| ឈ្មោះសិស្ស៖ | ថ្ងៃខែឆ្នាំកំណើត៖ |
| សាលារៀន៖ | កម្រិតថ្នាក់រំពឹងទុក៖ |

**សូមឆ្លើយឱ្យបានគ្រប់សំណួរទាំងអស់ ដោយមិនត្រូវរំលងសំណួរណាមួយចោលឡើយ។**

1. តើកូនរបស់អ្នកនិយាយ ឬយល់ភាសាអ្វីខ្លះមុនគេ? ____________________

2. តើកូនរបស់អ្នកនិយាយ ឬយល់ភាសាអ្វីខ្លះបានងាយស្រួលជាងគេ? ____________________

3. តើមនុស្សទូទៅប្រើភាសាអ្វីខ្លះជាមួយកូនរបស់អ្នកប្រចាំថ្ងៃ? ____________________

សូមដាក់ឯកសារដើមនៃឯកសារដែលបានបំពេញនេះនៅក្នុងថតឯកសារកំណត់ត្រាអចិន្ត្រៃយ៍របស់សិស្ស

មូលដ្ឋានច្បាប់៖ ផ្នែកទី 3111 ច្បាប់អប់រំបឋមសិក្សា និងមធ្យមសិក្សា ឆ្នាំ 1965

# ការស្ទង់មតិអំពីការប្រើប្រាស់ភាសា

ហត្ថលេខាមាតាបិតា/អាណាព្យាបាល៖ ________________________ កាលបរិច្ឆេទ៖ ____________

---

**សម្រាប់ការប្រើប្រាស់របស់សាលារៀនបន្ទាប់ពីការកំណត់អត្តសញ្ញាណក្រោយចុះឈ្មោះសិស្សតែប៉ុណ្ណោះ៖**
ប្រសិនបើភាសាអង់គ្លេសគឺជាភាសាតែមួយគត់ដែលត្រូវបានកំណត់អត្តសញ្ញាណនៅក្នុងការស្ទង់មតិអំពីការប្រើប្រាស់ភាសានេះ (សំណួរទី 1-3 ខាងលើ) ការធ្វើតេស្តសមត្ថភាពភាសាអង់គ្លេស (ELP) អាចនឹងត្រូវបានអនុវត្ត **លុះត្រាណាតែ**ផ្នែកនេះត្រូវបានបំពេញដោយគ្រូបង្រៀន ហើយបន្ទាប់មកត្រូវបានអនុម័តដោយនាយកសាលា/អ្នកសម្របសម្រួលពហុភាសា ឬគណៈកម្មការចូលប្រើភាសា។
សូមពិពណ៌នាអំពីភស្តុតាងដែលបង្ហាញថា ការអភិវឌ្ឍន៍ភាសាអង់គ្លេសរបស់សិស្សត្រូវបានជះឥទ្ធិពលដោយសារភាសាកំណើត ឬភាសាដែលប្រើនៅផ្ទះដែលមិនមែនជាភាសាអង់គ្លេស៖

**ហត្ថលេខា៖** គ្រូ ________________________ កាលបរិច្ឆេទ៖ ____________

នាយក/អ្នកសម្របសម្រួលពហុភាសា ________________ កាលបរិច្ឆេទ៖ ____________

សូមដាក់ឯកសារដើមនៃឯកសារដែលបានបំពេញនេះនៅក្នុងថតឯកសារកំណត់ត្រាអចិន្ត្រៃយ៍របស់សិស្ស

មូលដ្ឋានច្បាប់៖ ផ្នែកទី 3111 ច្បាប់អប់រំបឋមសិក្សា និងមធ្យមសិក្សា ឆ្នាំ 1965